សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស
## ថ្ងៃ១០ ធ្នូ ១៩៤៨ (ត) ។

www.hoksavann.org

ថ្ងៃទី១០ មីនា ២០១២



តាមញាណទស្សនវិជ្ជារបស់ព្រះពុទ្ធសាសនាពោលថា មនុស្សនិងសង្គមមនុស្សចេះតែទាស់ទែងខ្វែងគំនិតគ្នារហូតដល់ប្រើហិង្សា ប្រើយុទ្ធវិធីកាប់សម្លាប់គ្នាពាសពេញពិភពលោកនេះ ដោយសារតែមនុស្សបុថុជ្ជនមាន លោភៈ ទោ សៈ មោហៈ ជាឫសគល់អកុសលនាំឲ្យមនុស្សសាងបាបកម្ម ។ ត្រង់ន័យនេះហើយ បានជាយើងឃើញសង្គ្រាមលោកទាំងពីរលើកសង្គ្រាមពីប្រទេសមួយទៅប្រទេសមួយ និងសង្គ្រាមក្នុងស្រុករបស់ខ្លួន ។ សម័យក្រោយមក មនុស្សមានការពិសោធន៍ មានការចេះដឹងកាន់តែជ្រៅជ្រះឡើង កើតមានមេត្តាអាណិតអាសូរដល់មនុស្សជាតិខ្លះ ដោយឃើញការបង្ហូរឈាមគ្នានេះ ដែលជាហេតុនាំឲ្យមនុស្សក្នុងសង្គមវិនាសអន្តរាយ ទើបកើតមានអង្គការសហប្រជាជាតិនេះឡើង ដើម្បីទប់កុំឲ្យមនុស្សក្នុងលោកបង្ហូរឈមគ្នា កុំឲ្យមនុស្សមានទំនាស់នឹងគ្នាងាកមករកការគោរពច្បាប់ ដោះស្រាយដោយសន្តិវិធីវិញ ។ ធម្មនុញ្ញនៃអង្គការសហប្រជាជាតិពុំមែនមានត្រឹ មតែ៣០មាត្រានេះទេ ដែលឲ្យមនុស្សគោរពសិទ្ធិមនុស្សលើសពីនេះទៅទៀត អង្គការសហប្រជាជាតិមានច្បាប់ជាច្រើនផ្នែកណាស់ ដែលព្រមព្រៀងគ្នាអនុម័តឡើង ដើម្បីដោះស្រាយជាផ្នែកៗ បើមានបញ្ហាកើតឡើង គេយកច្បាប់ទាំងនោះមកដោះស្រាយ ។ តទៅនេះ យើងសូមលើកយកធម្មនុញ្ញនៃសិទ្ធិមនុស្សមកផ្សាយជាបន្តទៀត ៖

★ មាត្រា២៧

១- បុគ្គលគ្រប់រូបមានសិទ្ធិដោយសេរី ចំពោះការរួមចំណែកក្នុងវិស័យវប្បធម៌របស់សហគមន៍, មានសិទ្ធិនិងទទួលចំណែកខាងសិល្បៈ, សិទ្ធិរួមចំណែកក្នុងវឌ្ឍនភាពនៃវិទ្យាសាស្ត្រ និងក្នុងគុណប្រយោជន៍ ដែលកើតចេញពីវឌ្ឍនភាពនេះ ។

២- បុគ្គលម្នាក់ៗមានសិទ្ធិការពារផលប្រយោជន៍ខាងសីលធម៌និងសម្ភារៈ ដែលផលិតចេញពីផលនៃវិទ្យាសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈ ដែលខ្លួនជាអ្នកបង្កើត ។

★ មាត្រា២៨

បុគ្គលគ្រប់រូបមានសិទ្ធិទាមទារ ឲ្យមានរបៀបរៀបរយខាងផ្លូវសង្គមកិច្ចនិងអន្តរជាតិ ដើម្បីឲ្យសិទ្ធិនិងសេរីភាពដែលចែងនៅក្នុងសេចក្តីប្រកាសនេះ កើតមានឡើងយ៉ាងពេញបរិបូណ៌

★ មាត្រា២៩

១- បុគ្គលម្នាក់ៗមានករណីយកិច្ចចំពោះសហគមន៍ ដែលជាកន្លែងតែមួយគត់បង្កើតនូវការរីកចំរើនពេញបរិបូណ៌ដោយសេរីនូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។

២- ក្នុងការប្រើសិទ្ធិនិងសេរីភាពនានា បុគ្គលម្នាក់ៗត្រូវតែស្ថិតនៅក្នុងព្រំដែនដែលច្បាប់បានចែងឡើង ដើម្បីធានាឲ្យមានការទទួលស្គាល់ និងការគោរពសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ ព្រមទាំងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃសីលធម៌នៃរបៀបរៀបរយសាធារណៈ និងនៃសុខមាលភាពទូទៅនៅក្នុងសង្គមមួយ ដែលមានលទ្ធិប្រជាធិបតេយ្យតែប៉ុណ្ណោះ ។

៣- ក្នុងករណីណាក៏ដោយ សិទ្ធិនិងសេរីភាពទាំងនេះមិនអាចយកទៅប្រើផ្ទុយពីគោលបំណង និងគោលការណ៍របស់សហប្រជាជាតិឡើយ ។

★ មាត្រា៣០

គ្មានបទបញ្ញត្តិណាមួយនៃសេចក្តីប្រកាសនេះ ដែលបកស្រាយឲ្យរដ្ឋមួយក្រុមមួយ ឬបុគ្គលណាម្នាក់មានសិទ្ធិធ្វើសកម្មភាពអ្វី ឬប្រព្រឹត្តអំពើអ្វី សំរាប់ទៅបំផ្លាញសិទ្ធិនិងសេរីភាពទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះឡើយ ។

នេះជាធម្មនុញ្ញនៃសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិទាំង៣០មាត្រា ដែលបានប្រកាសជាសាកលថ្ងៃ១០ ធ្នូ ១៩៤៨ ឲ្យមនុស្សក្នុងសកលលោកប្រតិបត្តិតាម ដើម្បីឲ្យសង្គមមនុស្សរស់នៅជាមួយគ្នាបានសុខសន្តិភាព ។

តើរបបគ្រប់គ្រងរបស់ខ្មែរ មានការគោរពសិទ្ធិមនុស្សនេះ ឬទេ ? ធម្មនុញ្ញនៃសិទ្ធិមនុស្សនេះកើតឡើងនៅឆ្នាំ១៩៤៨ ដូច្នេះទាន់សម័យសង្គមរាស្ត្រនិយម ។ ដោយសេចក្តីសង្ខេប សម័យសង្គមរាស្ត្រនិយមមានការគោរពសិទ្ធិមនុស្សខ្លះ មិនគោរពខ្លះ ។ សម័យកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ដកសិទ្ធិមនុស្សនេះចេញទាំងស្រុង គឺមិនគោរពសិទ្ធិនេះឡើយ ដោយបញ្ចូលមកវិញនូវរបបកុម្មុយនិស្តផ្តាច់ការ លើសកុម្មុយនិស្តផ្តាច់ការម៉ៅ-សេទុងទៅទៀត ។ សម័យសាធារណរដ្ឋខ្មែរលោកសេនាប្រមុខលន់-នល់ជារបបសេរី នៅច្របូកច្របល់នឹងសង្គ្រាម ពិបាកវិនិច្ឆ័យឲ្យល្អឲ្យអាក្រក់ណាស់ ។ សម័យរដ្ឋកម្ពុជាអំឡុងឆ្នាំ១៩៨០ នៅក្នុងសង្គ្រាមដែរ តែនៅក្រោមការត្រួតត្រារបស់កងទ័ពវៀតណាម ។ របបនេះទោះបីមានទំនោរទៅរករបបសេរីខ្លះហើយក៏ដោយ ប៉ុន្តែនៅក្រោមការត្រួតត្រា និងចាត់ចែងរបស់កងទ័ពវៀតណាម ដូច្នេះត្រូវតែធ្វើតាមរបបកុម្មុយនិស្តវៀតណាម ។ បន្ទាប់ពីវៀតណាមប្រកាសដកទ័ព ចេញពីប្រទេសកម្ពុជាឆ្នាំ១៩៨៩ និងតាមកិច្ចព្រមព្រៀងសន្តិភាពថ្ងៃ២៣ តុលា ១៩៩១ និងរដ្ឋធម្មនុញ្ញខ្មែរឆ្នាំ១៩៩៣ចែងថា ខ្មែរកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស ហើយខ្មែរបានចុះហត្ថលេខាចាប់ពីឆ្នាំ១៩៩២មក នូវសន្ធិសញ្ញា អនុសញ្ញា កត្តិកាសញ្ញារបស់អង្គការសហប្រជាជាតិ ជាពិសេសទទួលស្គាល់នូវធម្មនុញ្ញនៃសិទ្ធិមនុស្សនេះ តើខ្មែរបានអនុវត្តត្រឹមត្រូវហើយឬនៅ ។៙